# អង្គរបុរី
## សម្លេងខ្មែរនៅបរទេស

# ការវិភាគ
## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទអំពីស្ថានសួគ៌នៅក្នុងព្រះពុទ្ធសាសនា

website: www.hoksavann.org

ថ្ងៃទី៧ កក្កដា ២០០៧



ស្ថានសួគ៌និងអ្នកដែលទៅកើតក្នុងស្ថានសួគ៌ ដែលមាននិយាយក្នុងព្រះពុទ្ធសាសនា គឺជាតួព្រះពុទ្ធដីកា ពុំមែនអដ្ឋកថាសំដែងទេ ហើយស្ថានសួគ៌និងអ្នកដែលទៅកើតក្នុងទីនោះ គឺកើតឡើងដោយកុសលកម្មដែលមនុស្សសត្វបានកសាង ពុំមែនកើតឡើងពីព្រះម្ចាស់អង្គណាបង្កើតឡើង សំរាប់ផ្តល់រង្វាន់ឲ្យដល់អ្នកជឿឡើយ ។ ពាក្យថា សួគ៌ឬស្ថានសួគ៌នេះ ជាពាក្យខ្មែរដែលចេញពីភាសាសំស្ក្រឹតថា សគ៌ៈ បាលីថា សគ្គៈ ដែលចែកចេញជាពីរពាក្យ គឺ<ស>មួយបទ និង<គ្គ>មួយបទ។ <ស> សព្ទដើមជា <សុ> ប្រែថាល្អ ស្អាត ឬងាយ ។ ឯ <គ្គ> សព្ទដើមជា <អគ្គៈ> ប្រែថាចុង កំពូល ឬលើស ។ រួមពាក្យទាំងពីរ គឺ<ស>និង<គ្គ> ជា<សគ្គៈ> ប្រែថា ល្អលើស ស្អាតលើស ងាយលើស គឺល្អស្អាតងាយលើសផ្លូវលោក ដោយរូប សម្លេង ក្លិន រស សម្ផស្ស ទ្រព្យ យស សុខ សរសើរ អាយុ ពណ៌សម្បុរជាដើម ។ ស្ថានសួគ៌ក៏ដូចជាស្ថាននរកដែរ មាននិយាយក្នុងគម្ពីរព្រះត្រៃបិដក ជាគម្ពីរដ៏ធំរបស់ព្រះពុទ្ធសាស-នា ។ ពួកទេវតានិងស្ថានសួគ៌ ត្រូវព្រះពុទ្ធសំដែងដោយផ្ទាល់ ហើយអដ្ឋកថាយកមកសំដែងពង្រីកសេចក្តីបន្ថែមទៀត ។ ក្នុងកាមាវចរកុសលមាននិយាយពីស្ថានសួគ៌៦ជាន់ ហើយថាព្រះពុទ្ធបានយាងទៅប្រោសពុទ្ធមាតានៅស្ថានត្រៃត្រឹង្ស ជាស្ថានសួគ៌ជាន់ទី២ផង ។ ពុទ្ធកិច្ច៥របស់ព្រះពុទ្ធមាននិយាយថា ពេលពាក់កណ្តាលអាធ្រាត្រស្ងាត់ ព្រះអង្គបានដោះស្រាយប្រស្នារបស់ពពួកទេវតាទាំងឡាយ ដែលបានមកសាកសួរព្រះអង្គ ដូចមានក្នុងសូត្រជាច្រើន មានមង្គលសូត្រជាដើម ។ នៅក្នុងព្រះសូត្រទាំងនោះ ក៏មានពាក្យរបស់ទេវតា ដែលបញ្ចេញទស្សនៈរបស់ខ្លួនដែលហៅថា ទេវតាសុភាសិត ហើយព្រះពុទ្ធបានពោលតែពាក្យរបស់ទេវតាទាំងនោះផង ។

មនុស្សសត្វដែលបានកើតក្នុងស្ថានសួគ៌ ដោយបានប្រព្រឹត្តតាមទេវធម៌ កីធម៌សំរាប់ទៅកើតជាទេវតា ។ ទេវធម៌ គឺអ្នកមានហិរិឱត្តប្ប: ខ្មាស់បាប ខ្លាចបាបមិនហ៊ានធ្វើ អ្នកមានសីល៥ មានការមិនសម្លាប់សត្វ បំបាត់ជីវិតគេជាដើម ។ អ្នកបំរើមាតាបិតាឲ្យគាត់រស់នៅបានសុខបានស្រួល ព្រមទាំងញ៉ាំងគាត់ឲ្យស្ថិតនៅក្នុងសទ្ធាសម្បទា សីលសម្បទា ចាគសម្បទា និងបញ្ញាសម្បទា ។ ធ្វើទានរក្សាសីល គោរពសមណ: អ្នកមានគុណធម៌ មានសីលធម៌ជាដើម ។ ធ្វើសាធារណ:ប្រយោជន៍ដល់ជនដទៃ ដោយការអាណិតអាសូរចំពោះជនដែលមានសេចក្តីទុក្ខលំបាក ។

ចំពោះសំនួរថា បើស្ថានសួគ៌មានពិតមែន តើស្ថិតនៅទីណា ព្រោះគេពុំឃើញមាននៅក្នុងផែនទីពិភពលោកឡើយ ? តាមពិត ស្ថានសួគ៌ផ្សេងពីស្ថានមនុស្ស តែស្ថិតនៅលើដីជាមួយមនុស្ស ។ ស្ថាន៦ជាន់ក្នុងកាមលោក ស្ថានព្រហ្មមានរូប១៦ជាន់ ជារូបព្រហ្ម និងអរូបព្រហ្ម៤ជាន់ ស្ថិតនៅទាក់ទងនឹងផែនដី ។ ក៏ដូចគ្នានឹងរុក្ខទេវតា គឺទេវតាអាស្រ័យនៅនឹងដើមឈើ ភុម្មទេវតា គឺទេវតាស្ថិតនៅអាស្រ័យដីស្រែចំការ សុទ្ធតែស្ថិតនៅទាក់ទងនឹងផែនដី ។ ធម៌សគ្គេកាមេ ដែលព្រះសង្ឃសូត្រពេលចំរើនព្រះបរិត្តបកប្រែថា ទេវតាទាំងឡាយដែលស្ថិតនៅក្នុងស្ថានសួគ៌ ដែលជាកាមភពនិងរូបភពក្តី ភូមិទេវតាតាំងឡាយ ដែលស្ថិតនៅក្នុងទិព្វវិមាន គឺលើកំពូលភ្នំ ឬភ្នំដែលដាច់ក្តី ឰដ៏អាកាសក្តី នៅនាកោះនិងដែននិងស្រុកក្តី នៅនាដើមព្រឹក្សានិងព្រៃញាតស្បាត ឬទីស្រែចំការក្តី ប៉ុណ្ណេះជាដើមបញ្ជាក់ថាទេវតាស្ថិតនៅទាក់ទងនឹងផែនដី ។ មនុស្សពុំអាចមើលឃើញពួកទេវតាទាំងនោះ ដោយមំសចក្ខុ គឺសាច់ភ្នែកធម្មតាបានឡើយ ព្រោះមានធាតុខុសគ្នា ប៉ុន្តែគេអាចឃើញឬដឹងបាន តាមរយ:ការអប់រំផ្លូវចិត្ត តាមវិធីសមថ:និងវិបស្សនា រហូតកើតទិព្វចក្ខុផ្នែកអភិញ្ញា ។ ពួកទេវតាត្រូវផុតវិស័យវិទ្យាសាស្ត្រ ដែលអាចពិសោធឃើញតាមភ្នែកធម្មតា ឬតាមឧបករណ៍អតិសុខុមទស្សន៍ ។ មានសេចក្តីបញ្ជាក់ក្នុងព្រះអភិធម្មនៃគម្ពីរព្រះពុទ្ធសាសនាថា កាមាវចរសត្វមុននឹងដាច់ខ្យល់ស្លាប់ ត្រូវតោងយកនិមិត្ត៣ និមិត្តណាមួយដើម្បីចាប់បដិសន្ធិ គឺកម្ម, កម្មនិមិត្ត និងគតិនិមិត្ត ។ គតិ-និមិត្តផ្នែកកុសល ឃើញទេវតាយករាជរថមកទទួល ឮសម្លេងដូរ្យតន្ត្រី លុះមនុស្សស្លាប់ទៅ ក៏ទៅកើតជាទេវតា ។ មានសេចក្តីតំណាលក្នុងជាតកថា ភិក្ខុមួយអង្គបានចំរើនធម៌ កើតទិព្វចក្ខុ ក្រឡេកមើលលើផែនដី ឃើញវិមានទេវតានៅពាសពេញ កាលពុំទាន់កើតទិព្វចក្ខុគ្មានឃើញវិមានទេវតាទាំងនោះសោះ ។ ព្រះនាមរបស់ព្រះពុទ្ធមួយបទថា លោកវិទូ ប្រែថាព្រះអង្គជ្រាបច្បាស់នូវលោក គឺជ្រាបនូវមនុស្សលោក ទេវលោក យមលោកគឺនរក និងព្រហ្មលោក ។ គេពុំអាចបដិសេធថា គ្មាននូវអ្វីដែលខ្លួនពុំបានឃើញនោះឡើយ ព្រោះរបស់ខ្លះមានពិតតាមសភាពខ្លួនវា មានស្ថានសួគ៌ស្ថាននរកជាដើម ប៉ុន្តែមើលពុំឃើញដោយខ្វះសមត្ថភាពដែលនាំឲ្យមើលឃើញ ។ អ្នកខ្លះយល់ថា

អ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ មានវិទ្យា មានបុណ្យស័ក្តិ មានអំណាចនោះឯង ជាទេវតាជាស្ថានសួគ៌ ។ តាមពិត ក្នុងពុទ្ធសាសនាមាននិយាយអំពីពាក្យសម្មតិទេព គឺទេវតាដោយសន្មតិនោះ សំដៅយកអ្នកមានធម៌ក្នុងខ្លួន មានហិរិឱត្តប្ប: ខ្លាស់បាប ខ្លាចបាប ប្រព្រឹត្តទេវធម៌ ជាធម៌ទេវតានៅលើផែនដីនៃមនុស្សលោក ។ ឯពាក្យមួយទៀតហៅថាឧបត្តិទេព គឺទៅកើតជាទេវតាក្នុងស្ថានសួគ៌ បន្ទាប់ពីអ្នកនោះស្លាប់ទៅ ។ ចំណែកអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ មានអំណាចបុណ្យស័ក្តិខ្ពង់ខ្ពស់ បើរបស់និងអំណាចទាំងនោះបានមកដោយអំពើទុច្ចរិត គ្មានហិរិឱប្ប:ទេ នោះពុំមែនជាអំណើប្រព្រឹត្តទៅដើម្បីស្ថានសួគ៌ទេ គឺជាអំពើប្រព្រឹត្តទៅដើម្បីស្ថាននរកវិញទេ ។ ដូច្នេះស្ថានសួគ៌ពិតជាមានសំរាប់អ្នកសាងកុសល គឺដូចជានរកពិតជាមានសំរាប់អ្នកសាងអកុសល ដែលស្ថិតនៅទាក់ទងនឹងផែនដី ដែលមនុស្សពុំអាចមើលឃើញឡើយ ។ ស្ថានសួគ៌៦ជាន់ខ្ពស់ទាបជាងគ្នាដោយឋាន: គឺបុណ្យកុសលដែលខ្លួនបានកសាង ពុំមែនខ្ពស់ទាបដោយទីកន្លែងឡើយ ។ ឯរុក្ខទេវតា អាកាសទេវតា ភុម្មទេវតា មានបុណ្យតិចជាងទេវតា៦ជាន់ខាងលើនេះ ។ ដូចមនុស្សបច្ចុប្បន្ននេះ អ្នកធំអ្នកតូច អ្នកមានអ្នកក្រ ស្ថិតនៅលើដីដូចគ្នា ។ ចំពោះទេវតា៦ជាន់ ដែលហៅថាទេវតាក្នុងឆកាមាសួគ៌៦ជាន់គឺ ទេវតាស្ថិតនៅជាន់ចាតុម្មហានាជិកា តាវត្តិង្ស យាមាតុសិត និម្មានរតី និងបរនិម្មិតវសត្តី ថានៅលើភ្នំព្រះសុមេរុនោះ មានអ្នកខ្លះបញ្ចេញទស្សន:ថា តើស្ថានសួគ៌និងទេវតានោះស្ថិតនៅនិងរស់នៅដូចម្តេចកើត បើទីនោះមានសុទ្ធតែទឹកកក បានអ្វីទទួលទាន ។ ទស្សន:នេះគេដោះស្រាយ ទេវតាដូចជាមនុស្ស តាមពិតទេវតាសោយទិព្វសម្បត្តិ ទាំងទីកន្លែង ទាំងចំណីអាហារ ទាំងការសប្បាយ និងកាមគុណ ពុំមែនដូចមនុស្សទេ ។ បើស្ថានសួគ៌៦ជាន់នោះស្ថិតនៅលើភ្នំព្រះសុមេរុពិតមែននោះ ពុំមែនស្ថិតនៅលើភ្នំតាមភ្នែកមើលឃើញនោះទេ គឺជាស្ថានមួយផ្សេង ដែលភ្នែកធម្មតាមើលពុំឃើញ ដូច្នេះមិនត្រូវយកភ្នែកធម្មតាមកដោះស្រាយបដិសេធនូវភាពអាថ៌កំបាំងនេះឡើយ ។៚

❄ ❄

❄